អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

# អត្ថបទប្រចាំខែ

លេខ ២០/២៣ ចេញផ្សាយ ខែសីហា ឆ្នាំ២០២៣

# ប្រភេទនៃផែនការប្រតិបត្តិការ




ការរៀបចំផែនការរបស់ស្ថាប័នពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីកំណត់អំពីអ្វីដែលស្ថានប័នចង់បានកំណត់ជាគោលដៅរួម និងគោលបំណងក្នុងការសម្រេចគោលដៅ និងគោលបំណងប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពរបស់ស្ថាប័នត្រូវរៀបចំនូវសកម្មភាពជាច្រើនជួយឱ្យសម្រេចនូវគោលដៅ និងគោលបំណងដែលបានកំណត់។ ជាមួយគ្នានេះ ការរៀបចំផែនការត្រូវយកចិត្តទុកដាក់ដោយកំណត់ច្បាស់ពីរយៈពេលត្រូវអនុវត្ត និងប្រើសម្រាប់ធ្វើជាបទពិសោធន៍ឱ្យសកម្មភាពដទៃទៀត។ ជាទូទៅ ការរៀបចំផែនការមាន **៣ ប្រភេទ**ដូចជា÷

**ក. ផែនការរយៈពេលវែង (៥ឆ្នាំ ឬ ១០ឆ្នាំ)**

ការរៀបចំផែនការរយៈពេលវែងមានដូចជា ផែនការយុទ្ធសាស្ត្រ ឬផែនការអភិវឌ្ឍន៍ស្ថាប័ន។ ការរៀបចំផែនការរយៈពេលវែងនេះ ជាការរៀបចំផែនការដោយផ្តោតលើការសម្រេចឱ្យបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ន ហើយការអនុវត្តសកម្មភាពនេះជាទូទៅត្រូវចំណាយពេល ៥ ឆ្នាំ ឬច្រើនបំផុត១០ឆ្នាំ។ ការរៀបចំផែនការអនាគតរយៈពេលវែងបង្កើតឡើងដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។

**ខ. ផែនការរយៈពេលមធ្យម (២ឆ្នាំ ឬ ៣ឆ្នាំ)**

ការរៀបចំផែនការរយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាពបីឆ្នាំរំកិល÷ ការរៀបចំផែនការរយៈពេលមធ្យមនេះ ជាការរៀបចំផែនការដោយផ្តោតលើការសម្រេចឱ្យបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ន ហើយការអនុវត្តសកម្មភាពនេះជាធម្មតាត្រូវបានចំណាយពេល ២ឆ្នាំ ឬ ៣ឆ្នាំ។ ការរៀបចំផែនការរយៈពេលមធ្យមជាទូទៅជួយឱ្យថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ និងបុគ្គលទទួលបន្ទុក អនុវត្តការងារកាន់តែយល់ច្បាស់នូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពកំណត់យ៉ាងច្បាស់នូវតម្រូវការប្រើប្រាស់ធនធានចាំបាច់បំផុត កាត់បន្ថយហានិភ័យនៅពេលដែលអាចធ្វើទៅបាន និងរៀបចំផែនការយថាភាពនៅពេលចាំបាច់។

**គ. ផែនការរយៈពេលខ្លី (១ឆ្នាំ ឬតិចជាង)**

ការរៀបចំផែនការរយៈពេលខ្លី ហៅថាការរៀបចំផែនការសកម្មភាពអនុវត្តប្រចាំឆ្នាំ÷ ជាការរៀបចំផែនការសកម្មភាពដោយផ្តោតលើការសម្រេចឱ្យបាននូវគោលដៅគោលបំណងរបស់ស្ថាប័ន ហើយការអនុវត្តសកម្មភាពនេះធម្មតាត្រូវបានចំណាយពេល ១២ខែ ឬតិចជាងនេះ។ ផែនការនេះត្រូវកំណត់នូវសកម្មភាព នៃការអនុវត្តការងារជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ សូម្បីតែប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់បុគ្គលទទួលបន្ទុកអនុវត្តការងារទាំងអស់អាចត្រូវបានចាត់ទុកថាជា “**ផែនការរយៈពេលខ្លី**”។

***អត្ថបទ÷ លោក ភាន់ សុភាក់***

***ឯកសារយោង÷*** *ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បោះផ្សាយឆ្នាំ២០២៣*

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ.
ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។
ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត
www.iauoffsa.gov.kh